អន្តរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ឯកសារមុនសន្និសិទអន្តរជាតិថ្ងៃ ២៣តុលា១៩៩១នៅទីក្រុងប៉ារីសស្តីអំពីកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជា ។

website: www.hoksavann.org

ថ្ងៃទី៣០ តុលា ២០០៧



កិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយរួមនៃវិវាទនៅកម្ពុជាបានចែងជាដំបូងថា រដ្ឋទាំងអស់ដែលចូលរួមក្នុងសន្និសិទប៉ារីសស្តីពីកម្ពុជាមានចំនួន១៩ប្រទេស នៅចំពោះមុខវត្តមាននៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីទ្រទ្រង់ថែរក្សាព្រមទាំងការពារនូវអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនឈ្លានពានទឹកដី អព្យាក្រឹត្យ និងឯកភាពជាតិនៃកម្ពុជា ។

ដោយមានបំណងស្តាបនាឡើងវិញ ព្រមទាំងទ្រទ្រង់សន្តិភាពនៅកម្ពុជា ញុំាំងឲ្យមានការបង្រួបបង្រួមជាតិ និងធានាដល់ពលរដ្ឋកម្ពុជា នូវការប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយខ្លួនឯង តាមរយៈការបោះឆ្នោតដោយសេរីនិងដោយយុត្តិធម៌ ។

ដោយជឿជាក់ថា មានតែដំណោះស្រាយរួមនៃវិវាទនៅកម្ពុជាប៉ុណ្ណោះទើបត្រឹមត្រូវនិងស្ថិតស្ថេរយូរអង្វែង ក្នុងការផ្តល់ជាវិភាគទានសំរាប់សន្តិភាពនិងសន្តិសុខប្រចាំតំបន់និងលើផ្ទៃរាបអន្តរជាតិបាន ។

ដោយស្វាគមន៍ចំពោះឯកសារក្របខណ្ឌ ចុះថ្ងៃ២៨សីហា១៩៩០ ដែលភាគីកម្ពុជាទាំងអស់បានព្រមព្រៀងលើឯកសារទាំងមូល ចាត់ទុកជាក្របខណ្ឌនៃបទបញ្ញត្តិក្នុងវិវាទនៅកម្ពុជា ដែលបន្ទាប់មកត្រូវបានយល់ព្រមជាឯកច្ឆន្ទដោយក្រុមប្រឹក្សាសន្តិសុខ តាមសេចក្តីសំរេចចិត្តលេខ៦៦៨ ចុះថ្ងៃ២០កញ្ញា១៩៩០ ។ ដោយមហាសន្និបាតអង្គការ

សហប្រជាជាតិ តាមសេចក្តីសំរេចចិត្តលេខ៤៥/៣ ចុះថ្ងៃ១៥តុលា១៩៩០ ។

ដោយកត់សំគាល់ឃើញ ការបង្កើតនៅហ្សាការតាថ្ងៃ១០កញ្ញា១៩៩០ នូវឧត្តមក្រុមប្រឹក្សាជាតិ ជាអង្គការស្របច្បាប់តែមួយ និងជាប្រភពនៃរដ្ឋអំណាចនៅកម្ពុជា ដែលក្នុងរយៈពេលអន្តរកាល ជានិមិត្តរូបនៃអធិបតេយ្យនិងឯកភាពជាតិ ព្រមទាំងជាតំណាងកម្ពុជានៅបរទេស ។

ដោយស្វាគមន៍ដល់ការសំរេចជាឯកច្ឆន្ទ នៅប៉េកាំងថ្ងៃ១៨កក្កដា១៩៩១ ក្នុងការតែងតាំងសម្តេចនរោត្តម-សីហនុ ជាប្រធានឧត្តមក្រុមប្រឹក្សាជាតិ ។ ដោយទទួលស្គាល់នូវតួនាទីដ៏ទូលំទូលាយរបស់អង្គការសហប្រជាជាតិ ដែលចាំបាច់ត្រូវបង្កើតឲ្យមានជាអាជ្ញាធរបណ្តោះអាសន្នមួយនៃអង្គការសហប្រជាជាតិនៅកម្ពុជា ដែលត្រៀមខ្លួនទាំងផ្នែកយោធា ទាំងផ្នែកស៊ីវិល បំរុងនឹងចូលអន្តរាគមន៍ ដោយគោរពទាំងស្រុងដល់អធិបតេយ្យជាតិកម្ពុជា ។

ដោយកត់សំគាល់នូវសេចក្តីថ្លែងការណ៍គ្រប់ការប្រជុំទាំងអស់ ជាអាទិនៅហ្សាការតា នៅថ្ងៃ៩និង១០កញ្ញា១៩៩០, នៅប៉ារីសថ្ងៃ២១និង២២ធ្នូ១៩៩០, នៅប៉ាតាយ៉ាថ្ងៃ២៤និង២៦មិថុនា១៩៩១, នៅប៉េកាំងថ្ងៃ១៦និង១៧កក្កដា១៩៩១, នៅប៉ាតាយ៉ាថ្ងៃ២៦និង២៧សីហា១៩៩១, នៅហ្សាការតាថ្ងៃ៤និង៦មិថុនា១៩៩១ និងនៅញូវយ៉កថ្ងៃ១៩តុលា១៩៩១ ។

ដោយស្វាគមន៍ដល់សេចក្តីសំរេចចិត្តលេខ៧១៧ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅថ្ងៃ១៦តុលា១៩៩១ ស្តីពីកម្ពុជា ។ ដោយទទួលស្គាល់នូវប្រវត្តិសាស្ត្រដែលជិតដាមទៅដោយសោកនាដ្យកម្មនាពេលថ្មីៗនៅកម្ពុជា ដែលកំពុងស្រែកដង្ហោយហៅរកវិធានការពិសេស ដើម្បីធានានូវកិច្ចការពារសិទ្ធិមនុស្ស ព្រមទាំងទប់ទល់មិនឲ្យនយោបាយនិងការប្រព្រឹត្តពីមុនៗវិលត្រឡប់មកវិញបាន ។

នេះជាសេចក្តីរៀបរាប់ជាដំបូង បន្ទាប់មកទើបមានសេចក្តីព្រមព្រៀង ចាត់ជាភាគជាជំពូក ជាមាត្រាជាច្រើនប្រការទៀត ។

សេចក្តីប្រកាសជាដំបូង ភ្ជាប់និងសេចក្តីយោងផ្សេងៗនេះបញ្ជាក់ថា មុននឹងមានការព្រមព្រៀងគ្នានេះ ត្រូវចំណាយពេលរាប់ឆ្នាំ ប្រជុំចុះប្រជុំឡើងរវាងភាគីខ្មែរខ្លួនឯងដើម្បីធ្វើការសម្របសម្រួលគ្នា ឆ្ពោះទៅរកឯកភាពជាតិខ្លួន ប្រទេសសមាគមអាស៊ីអាគ្នេយ៍ សហប្រធានទាំងពីរនៃសន្និសិទអន្តរជាតិស្តីពីកម្ពុជា បានខំប្រឹងប្រែងខ្នះខ្នែង និងឧបត្ថម្ភយ៉ាងពេញទំហឹង ឆ្ពោះទៅរកដំណោះស្រាយសន្តិភាពនៅកម្ពុជា ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ បានព្រមព្រៀងលើឯកសារទាំងមូល ។ មហាសន្និបាតនៃអង្គការសហប្រជាជាតិ ក៏បានធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួនចំពោះដំណោះស្រាយនេះ ។ ដូច្នេះការស្វែងរករូបមន្តដើម្បីសន្តិភាពនេះ ជាការពិបាកណាស់ ហើយពិបាកមួ

យទៀត គឺការអនុវត្តន៍ឲ្យបានត្រឹមត្រូវនូវរូបមន្តនេះ ។

តាមខ្លឹមសារនៃសន្និសិទអន្តរជាតិថ្ងៃ២៣តុលា១៩៩១នៅទីក្រុងប៉ារីសមាន៤ចំណុច គឺត្រូវដកទ័ពបរទេសទាំងអស់ចេញពីកម្ពុជា, ត្រូវដកអាវុធពីគ្រប់ភាគីខ្មែរ, ត្រូវបោះឆ្នោតដោយសេរីនិងយុត្តិធម៌ និងកសាងប្រទេសកម្ពុជាឡើងវិញ ។ ជាពិសេសតាមកិច្ចព្រមព្រៀង តម្រូវឲ្យការពារអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនឈ្លានពានទឹកដី អព្យាក្រឹត្យ និងឯកភាពជាតិនៃកម្ពុជា ត្រូវបានអនុវត្តដោយត្រឹមត្រូវហើយឬនៅ ។ រយៈកាលចំនួន១០ឆ្នាំក្រោមការត្រួតត្រារបស់កងទ័ពវៀតណាម សន្ធិសញ្ញាចំនួន៤បានត្រូវភាគីខ្មែរនិងវៀតណាមបានចុះហត្ថលេខា គឺទីមួយចុះហត្ថលេខានៅថ្ងៃ១៨កុម្ភៈ១៩៧៩ ដើម្បីមិត្តភាពនិងសហប្រតិបត្តិការ រវាងលោកហេង-សំរិននិងនាយករដ្ឋមន្ត្រីផាំង-យ៉ាំងដុងនៅភ្នំពេញ, ទីពីរកិច្ចព្រមព្រៀងព្រំដែនទឹកប្រវត្តិសាស្ត្រ ចុះហត្ថលេខានៅថ្ងៃ៧កក្កដា១៩៨២ រវាងលោកហ៊ុន-សែននិងលោកង្វៀង-កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសនៅទីក្រុងហូ-ជីមិញ, ទីបីសន្ធិសញ្ញាលើគោលការណ៍ដំណោះស្រាយព្រំដែន ចុះហត្ថលេខានៅថ្ងៃ២០កក្កដា១៩៨៣ រវាងលោកហ៊ុន-សែននិងង្វៀង-កូថាច់, ទីបួនសន្ធិសញ្ញាកំណត់ព្រំដែននៃជាតិទាំងពីរ ចុះហត្ថលេខានៅថ្ងៃ២៧ធ្នូ១៩៨៥ រវាងលោកហ៊ុន-សែននិងង្វៀង-កូថាច់ ។ តាមអ្នកជំនាញភូមិសាស្ត្រនិយាយថា យោងតាមសន្ធិសញ្ញាឆ្នាំ១៩៨២ កម្ពុជាត្រូវកាត់កោះត្រល់និងកោះច្រកសេះឲ្យទៅវៀតណាម ។ សន្ធិសញ្ញាឆ្នាំ១៩៨៣ អតីតនាយករដ្ឋមន្ត្រីចាន់-ស៊ី បានចេញសារាចរថ្ងៃ៩តុលា១៩៨៣ បើកព្រំដែនឲ្យជនជាតិវៀតណាម ចូលមករស់នៅកម្ពុជាតាមច្រកចំនួន៨ ។

តាមកិច្ចព្រមព្រៀងសន្តិភាពថ្ងៃ២៣តុលា១៩៩១នៅទីក្រុងប៉ារីស បានធានាការពារនូវអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនឈ្លានពានទឹកដី ។ តើខ្មែរខ្លួនឯងបានចាត់ទុកនូវសន្ធិសញ្ញាខុសច្បាប់ទាំងនោះជាមោឃៈហើយឬនៅ ។ មិនត្រឹមតែមិនចាត់ទុកជាមោឃភាពនូវសន្ធិសញ្ញាទាំងនោះទេ ថែមទាំងធ្វើសន្ធិសញ្ញាឆ្នាំ១៩៨៥ ដែលមិនស្របច្បាប់ថែមទៀត ។ បញ្ហាជាអាយុជីវិតជាតិនេះ ជាភារកិច្ចរបស់ជនជាតិខ្មែរគ្រប់រូបទាំងក្នុងនិងក្រៅប្រទេស នាំគ្នាដោះស្រាយជាបន្ទាន់ ដើម្បីកុំឲ្យខ្មែរបាត់បង់ទឹកដីតទៅទៀត ។៚